# ព្រឹត្តិប័ត្រព័ត៌មានជំងឺឆ្លង

## នៅព្រះរាជាណាចក្រកម្ពុជា

**Cambodia Communicable Disease Bulletin**


# ផ្តាសាយប្រភេទថ្មី A (H1N1)

## សំនួរដែលគេតែងសួរញឹកញាប់ :

### អ្វីទៅជាការរាតត្បាតជាសកល?

ការរាតត្បាតជាសកល គឺជាការផ្ទុះជំងឺឆ្លងជាសកលមួយ។ ការរាតត្បាតជាសកល គឺជាការឆ្លុះបញ្ចាំងអំពីការ រាលដាលជំងឺឆ្លងជាអន្តរជាតិ ដោយមិនពាក់ព័ន្ធជាមួយនឹងភាពធ្ងន់ធ្ងររបស់ជំងឺ។

### អ្វីទៅជាការរាតត្បាតជាសកលនៃជំងឺផ្តាសាយ?

ការរាតត្បាតជាសកលនៃជំងឺផ្តាសាយ កើតឡើងនៅពេលវីរុសផ្តាសាយ ប្រភេទថ្មី លេចរូបរាង ឡើងហើយបន្ទាប់មកអាចឆ្លងរាលដាលពីមនុស្សម្នាក់ ទៅមនុស្សម្នាក់ទៀត បានយ៉ាងងាយ នៅទូទាំងពិភពលោក។ វីរុសថ្មីនេះ ឆ្លងរាលដាលយ៉ាងងាយ ដោយសារតែមនុស្សភាគច្រើន មិនមានភាពស៊ាំនឹងវា។

### តើការរាតត្បាតជាសកលនៃជំងឺផ្តាសាយ កើតឡើងញឹកញាប់កំរិតណា និង តើការរាតត្បាតជាសកលទាំងនេះ មានគ្រោះថ្នាក់កំរិតណា?

ការរាតត្បាតជាសកលនៃជំងឺផ្តាសាយ កម្រកើតមានឡើងណាស់ ប៉ុន្តែជាព្រឹត្តិការណ៍ដែលកើតឡើងហើយ កើតទៀត។ នៅក្នុងរយៈពេល ១០០ ឆ្នាំចុងក្រោយនេះ មានការរាតត្បាតជាសកលនៃជំងឺផ្តាសាយកើត ឡើង ៣ ដង គឺនៅក្នុងឆ្នាំ ១៩៦៨ ១៩៥៧ និង ១៩១៨។

ការរាតត្បាតជាសកលទាំង ៣ នេះ បង្កឡើងដោយវីរុសប្រភេទថ្មីៗ ដែលមានលក្ខណៈជាច្រើនខុសពីគ្នា ជា ពិសេស ភាពធ្ងន់ធ្ងររបស់វា។

## មាតិកាអត្ថបទ


១.ផ្តាសាយប្រភេទថ្មី A (H1N1) ទំព័រទី១-៣

២.ការការពារ ការបង្ការ និង ការព្យាបាល ទំព័រទី ៤-៥

៣.ការឆ្លើយតបរបស់រដ្ឋាភិបាល ចំពោះផ្តាសាយប្រភេទថ្មី A(H1N1) ទំព័រទី ៦

៤.របាយការណ៍ និង ផែនទី ចំនួនករណីឈឺនិងស្លាប់ នៃជំងឺផ្តាសាយថ្មី A (H1N1) លើពិភពលោក ទំព័រទី ៧-៨



នាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លង ក្រសួងសុខាភិបាល ១៥១-១៥៣ វិថីកម្ពុជាក្រោម រាជធានីភ្នំពេញ

ទូរស័ព្ទលេខ និង ទូរសារ (៨៥៥-២៣) ៩២៧ ៨១៧

ឆ្នាំទី ៦ លេខ ៥

ការរាតត្បាតជាសកលនៃជំងឺផ្តាសាយ អាចមានកំរិតស្រាល (នៅពេលដែល មនុស្សភាគច្រើនដែលឆ្លងអាចធូរស្រាល មកវិញយ៉ាងពេញលេញ) ឬ អាចមានកំរិតធ្ងន់ធ្ងរ (ធ្វើអោយមាន បញ្ហាផ្លូវដង្ហើមធ្ងន់ធ្ងរនិងអាចបង្កអោយស្លាប់)។ ឧទាហរណ៍ វីរុសរាតត្បាតជាសកលនៅក្នុងឆ្នាំ ១៩១៨ មានកំរិតធ្ងន់ធ្ងរដោយបានធ្វើអោយមានគ្រោះមហន្តរាយយ៉ាងធំសម្បើម ដែលបាន ធ្វើអោយមនុស្សស្លាប់ ពី ២០-៤០ លាននាក់ ខណៈពេលដែលការរាតត្បាតជាសកលក្នុងឆ្នាំ ១៩៥៧ និង ១៩៦៨ មានកំរិតស្រាលជាង ច្រើនដែលបានធ្វើអោយមានមនុស្សស្លាប់តែ ២-៤ លាននាក់។

បើយើងធ្វើការប្រៀបធៀប ទៅនឹងជំងឺផ្តាសាយធម្មតា សំលាប់មនុស្សប្រមាណ ៥ សែន ទៅ ១ លាននាក់ នៅទូទាំង សកលោកជារៀងរាល់ឆ្នាំ។

## តើការរាតត្បាតជាសកលមានប៉ុន្មានដំណាក់កាល?

អង្គការសុខភាពពិភពលោក (WHO) បានបង្កើតប្រព័ន្ធប្រកាសអាសន្ន ដែលមាន ៦ ដំណាក់កាល ដើម្បីជូនដំណឹង ដល់ពិភពលោកទាំងមូល អំពីការវិវត្តន៍នៃហានីភ័យរបស់ការរាតត្បាតជាសកល។

## តើឥឡូវនេះ យើងកំពុងស្ថិតនៅក្នុងដំណាក់កាលទីប៉ុន្មាន?

មុនថ្ងៃទី១១មិថុនា២០០៩ ពិភពលោកកំពុងស្ថិតនៅក្នុង**ដំណាក់កាលទី ៥** នៃការរាតត្បាតជាសកល ដែលមានន័យថា វីរុសថ្មីនេះ កំពុងតែកាន់តែរាលដាលពីកន្លែងមួយ ទៅកន្លែងមួយទៀត នៅទូទាំងពិភពលោក។ វីរុសថ្មីនេះ នៅមិនទាន់រាលដាល បន្តបន្ទាប់ឥតឈប់ឈរ ក្នុងប្រទេសនិងក្នុងតំបន់ ជុំវិញពិភពលោកក្នុងចំនួនគ្រប់គ្រាន់ ដើម្បីបង្កើនកំរិតស្ថានភាព អោយដល់ **ដំណាក់កាលទី ៦** ដែលជា "ការរាតត្បាតជាសកល" នោះទេ។ ប៉ុន្តែ ស្ថានភាពនេះពិតជាទំនងនឹងអាចកើតមានឡើង។

រដ្ឋាភិបាល កំពុងទទួលបានដំបូន្មានពីអង្គការសុខភាពពិភពលោក អោយប្រុងប្រយ័ត្នខ្ពស់ និងចាប់ផ្តើម អនុវត្តផែនការឆ្លើយតប ចំពោះការរាតត្បាតជាសកល របស់ពួកគេ។

## អ្វីទៅជាវីរុសផ្តាសាយប្រភេទ A (H1N1)?

វីរុសផ្តាសាយប្រភេទ គឺជាវីរុសផ្តាសាយមនុស្សប្រភេទថ្មី ដែលមានកំរិតចំលងខ្ពស់ ដែលអាចធ្វើអោយ ប៉ះពាល់ដល់ ប្រព័ន្ធផ្លូវដង្ហើម។

ដោយសារតែវីរុសនេះ គឺជាវីរុសផ្តាសាយមនុស្សប្រភេទថ្មី មនុស្សភាគច្រើននៅក្នុងសហគមន៍មានភាពស៊ាំ តិចតួច ឬ គ្មានភាពស៊ាំទាល់តែសោះ ទៅនឹងវីរុសផ្តាសាយប្រភេទ A (H1N1) នេះ។

## តើវីរុសផ្តាសាយប្រភេទ A (H1N1) មានគ្រោះថ្នាក់កំរិតណា?

នៅមិនទាន់អាចកំណត់បានតាមលក្ខណៈវិទ្យាសាស្រ្ត នៅដំណាក់កាលនេះនៅឡើយទេ ថាតើវីរុសផ្តាសាយ ប្រភេទ A (H1N1) ថ្មីនេះគឺជាវីរុសប្រភេទ "ស្រាល" ឬ "ធ្ងន់" ឬ ថាតើវានឹងមានការផ្លាស់ប្តូរ ក្នុងកំឡុងពេល ណាមួយនោះ។

## តើមានវីរុសផ្តាសាយ A (H1N1) នៅក្នុងប្រទេសកម្ពុជាដែរឬទេ?

រហូតមកដល់បច្ចុប្បន្ននេះ នៅមិនទាន់មានការរាយការណ៍អំពីករណីផ្តាសាយ A (H1N1) នៅក្នុងប្រទេស កម្ពុជានៅឡើយទេ។ វីរុសផ្តាសាយ A (H1N1) អាចនឹងមកដល់ប្រទេសកម្ពុជានាពេលអនាគត។

## ហេតុអ្វីបានជាខ្ញុំគួរត្រៀមរៀបចំពីឥឡូវនេះទៅ ប្រសិនបើគ្មានការផ្ទុះជំងឺផ្តាសាយថ្មីនេះ នៅក្នុងប្រទេសកម្ពុជាផង?

ដំណាក់កាលទី ៥ បង្ហាញថា ការរាតត្បាតជាសកលទំនងជានឹងកើតមានឡើង។ វីរុស អាចឆ្លងរាលដាលយ៉ាង លឿន ហើយធ្វើអោយមនុស្សធ្លាក់ខ្លួនឈឺ បង្ករអោយមានការរាំងស្ទះដំណើរការសង្គម និង សេដ្ឋកិច្ច។ ជា ការសំខាន់ ដែលប្រទេសកម្ពុជាត្រូវត្រៀមរៀបចំសំរាប់ការរាតត្បាតជាសកល ដែលអាចកើតមានឡើង មុនពេលដែលវាកើតមានឡើង។

## តើកន្លងមកមានជំងឺផ្តាសាយប្រភេទ A (H1N1) ប៉ុន្មានករណីហើយ និងនៅកន្លែងណាខ្លះ?

ស្ថានភាព មានការវិវត្តន៍ ជារៀងរាល់ថ្ងៃ។

អង្គការសុខភាពពិភពលោក ធ្វើបច្ចុប្បន្នភាពព័ត៌មានផ្លូវការ លើវ៉ិបសាយរបស់ខ្លួន www.who.int/csr/ ។

## ហេតុអ្វីបានជាជំងឺផ្តាសាយប្រភេទ A (H1N1) ត្រូវបានគេហៅថាជំងឺផ្តាសាយជ្រូក នៅពេល ទើបមាន ការ ផ្ទុះជំងឺនេះដំបូងៗ?

ដំបូង គេហៅជំងឺផ្តាសាយប្រភេទ A (H1N1) ថាជា "ជំងឺផ្តាសាយជ្រូក" ដោយសារតែការធ្វើតេស្តនៅក្នុងមន្ទីរ ពិសោធន៍បានបង្ហាញថា វីរុសថ្មីនេះ គឺស្រដៀងគ្នាទៅនឹងវីរុសផ្តាសាយដែលជាធម្មតាត្រូវបានគេរកឃើញ ក្នុងសត្វជ្រូក។

## ហេតុអ្វីបានជាគេប្តូរឈ្មោះវាទៅជាវីរុសផ្តាសាយប្រភេទ A (H1N1)?

អង្គការសុខភាពិភពលោក បានផ្លាស់ប្តូរឈ្មោះវីរុសថ្មីនេះ ជាផ្លូវការ ជាវីរុសផ្តាសាយប្រភេទ A (H1N1) ដើម្បី បញ្ជាក់ថា នេះគឺជាវីរុសមនុស្ស ដែលឆ្លងពីមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀត ហើយ នៅមិនទាន់មានការ បញ្ជាក់អំពីប្រភព ពិតប្រាកដ របស់វានៅឡើយទេ។

## តើការបរិភោគសាច់ជ្រូក មានសុវត្ថិភាពដែរឬទេ?

ការបរិភោគសាច់ជ្រូក គឺមានសុវត្ថិភាព។ មិនមានភស្តុតាងបង្ហាញថា វីរុសផ្តាសាយប្រភេទ A (H1N1) នេះ ឆ្លងដោយសារការបរិភោគសាច់ជ្រូកនោះទេ។ ប្រសិនបើសាច់ជ្រូក ឬ ផលិតផលមានដើមកំណើតពីសាច់ជ្រូក ត្រូវបានចំអិនត្រឹមត្រូវ (៧០ អង្សាសេ/១៦០ អង្សាហ្វារិនហៃ) នោះពុំមានគ្រោះថ្នាក់ ធ្វើអោយមនុស្សឆ្លង វីរុសនេះទេ។

# ការការពារ ការបង្ការ និង ការព្យាបាល

## តើវីរុសផ្តាសាយប្រភេទ A (H1N1) ឆ្លងរាលដាលដោយរបៀបណា?

វីរុសផ្តាសាយប្រភេទ A (H1N1) ឆ្លងពីមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀត តាមរយៈដំណក់ តូចៗនៃ សារធាតុរាវ ដែលចេញពីខ្លួនមនុស្ស ហើយមានផ្ទុកវីរុសនេះ នៅពេលដែលមនុស្សម្នាក់នោះកណ្តាស និយាយ ក្អក ឬ ខាកស្តោះ។

ប្រសិនបើ ដំណក់តូចៗនៃសារធាតុរាវ ទាំងនេះមាននៅលើផ្ទៃ ដូចជា តុ សម ស្លាបព្រា កំបិត និង ដៃទ្វារ ហើយ មានមនុស្សម្នាក់ទៀតមកប៉ះហើយយកដៃមកប៉ះមាត់ ឬ ច្រមុះខ្លួន ពួកគេអាចឆ្លងវីរុសនេះបាន។ វីរុសនេះអាចរស់នៅលើ ផ្ទៃរឹង ក្រណាត់ និងក្រដាស បានជាច្រើនម៉ោង។

## តើជំងឺផ្តាសាយប្រភេទ A (H1N1) មានរោគសញ្ញាអ្វីខ្លះ?

រោគសញ្ញានៃជំងឺផ្តាសាយប្រភេទ A (H1N1) ស្រដៀងគ្នានឹងជំងឺផ្តាសាយធម្មតាដែរ និងអាចមានរោគសញ្ញា ដូចជា ឡើងកំដៅខ្លួនភ្លាមៗ (៣៨ អង្សាសេ) ឈឺក្បាល ល្ហិតល្ហៃ ក្អក ឈឺក ហៀរសំបោរ រកកលចង់ក្អួត ក្អួត និង/ឬ រាក។

## តើខ្ញុំគួរធ្វើដូចម្តេច ដើម្បីការពារខ្លួនខ្ញុំនិងអ្នកដទៃទៀតមិនអោយឆ្លងជំងឺផ្តាសាយ ប្រភេទ A (H1N1) នេះ?

វិធីល្អបំផុតដើម្បីការពារខ្លួនអ្នកនិងអ្នកដទៃ គឺត្រូវអនុវត្តអនាម័យផ្ទាល់ខ្លួនអោយបានល្អគ្រប់ពេលទាំងអស់ និងត្រូវបង្រៀនពីទំលាប់ អនាម័យល្អៗទាំងនេះទៅកូនៗរបស់អ្នក។

ក្រសួងសុខាភិបាល បានផ្តល់ដំបូន្មានខាងក្រោមនេះ ជាការណែនាំអំពីអនាម័យសាធារណៈ :



- ខ្ទប់មាត់និងច្រមុះជាមួយក្រដាសនៅពេលក្អកនិងកណ្តាស
- លាងដៃអោយបានញឹកញាប់ជាមួយសាប៊ូ
- កុំខាកស្តោះនៅតាមទីសាធារណៈ

## តើខ្ញុំគួរពាក់ម៉ាស ដែលគេពាក់សំរាប់វះកាត់ ដែរឬទេ?

ការពាក់ម៉ាស មិនទំនងជានឹងជួយបង្ការការឆ្លងរាលដាលជំងឺផ្តាសាយប្រភេទ A (H1N1) បានឡើយ។ វិធី ដែលសំខាន់បំផុត ដើម្បីការពារខ្លួនអ្នកនិងអ្នកដទៃ គឺត្រូវធ្វើតាមការអនុវត្តអនាម័យល្អដូចខាងក្រោមៈ

- ខ្ទប់មាត់និងច្រមុះជាមួយក្រដាស នៅពេលក្អកនិងកណ្តាស ហើយចោលក្រដាសក្នុងធុងសំរាម
- លាងដៃអោយបានញឹកញាប់ជាមួយសាប៊ូ
- កុំខាកស្តោះ នៅតាមទីសាធារណៈ

## តើមានវ៉ាក់សាំងសំរាប់បង្ការជំងឺផ្តាសាយប្រភេទ A (H1N1) ដែរឬទេ?

ទេ ! គ្មានវ៉ាក់សាំងសំរាប់ជំងឺផ្តាសាយប្រភេទ A នេះទេ។

អង្គការសុខភាពពិភពលោក កំពុងធ្វើការងារជាមួយក្រុមហ៊ុន ដើម្បីផលិតវ៉ាក់សាំង។ ប៉ុន្តែវាត្រូវការយ៉ាង ហោចណាស់រយៈពេល

៤-៦ ខែ ដើម្បីបង្កើតវ៉ាក់សាំងនេះ ហើយវាកាន់តែយូរជាងនេះទៀតដើម្បីផលិត និងចែកចាយវ៉ាក់សាំងគ្រប់ចំនួនទៅតាមសេចក្តីត្រូវការ។

## តើមានថ្នាំណាខ្លះ សំរាប់ព្យាបាល?

រាជរដ្ឋាភិបាលមានថ្នាំបំរុងទុកក្នុងករណីមានការរាតត្បាតជាសកលនៃជំងឺផ្តាសាយនៅក្នុងប្រទេសកម្ពុជា។ ករណីជំងឺផ្តាសាយប្រភេទ A (H1N1) ដែលបានរាយការណ៍ភាគច្រើន បានធូរស្បើយទៅវិញយ៉ាងពេញលេញដោយមិនចាំបាច់ត្រូវការការព្យាបាល។

## តើប្រជាជនគួរធ្វើអ្វីខ្លះ នៅពេលដែលពួកគេគិតថា ពួកគេមានជំងឺផ្តាសាយប្រភេទ A ?

សាធារណៈជន ដែលគិតថាខ្លួនអាចមានជំងឺផ្តាសាយប្រភេទ A ជាពិសេសអ្នកដែលទើបធ្វើដំណើរទៅកាន់ តំបន់មានជំងឺ ត្រូវតែស្នាក់នៅក្នុងផ្ទះ ហើយទូរស័ព្ទទៅកាន់លេខទូរស័ព្ទទាន់ហេតុការណ៍ត្រៀមបង្ការការរាតត្បាតជាសកល របស់ក្រសួងសុខាភិបាល ០១២ ៤៨៨ ៩៨១ ឬ ០៨៩ ៦៦៩ ៥៦៧ ដើម្បីទទួលបាន ដំបូន្មានបន្ថែម។

## តើខ្ញុំគួរទៅកន្លែងណា ដើម្បីបានព័ត៌មានបន្ថែម?

នៅក្នុងពេលមានករណីអាសន្នផ្នែកសុខភាពសាធារណៈ ជាការសំខាន់ណាស់ដែលត្រូវស្វែងរកព័ត៌មានសុក្រឹត /ត្រឹមត្រូវអោយបានទៀងទាត់ ដើម្បីដឹងពីអំពីស្ថានភាព។

## គន្លឹះ៥យ៉ាងដើម្បីចំណីអាហារមានសុវត្ថិភាព និងអាចការពារពីជំងឺមកពីចំណីអាហារ

ជារៀងរាល់ថ្ងៃមានមនុស្សរាប់លាននាក់ធ្លាក់ខ្លួនឈឺ និងមនុស្សរាប់ពាន់នាក់ស្លាប់ដោយសារជំងឺមកពីចំណីអាហារដែលអាចការពារបាន ។ ការរៀបចំចំណីអាហារត្រឹមត្រូវ អាចការពារជំងឺមកពីចំពីអាហារជាច្រើន។ ពេលដែលផ្នែកមួយនៃយុទ្ធសាស្ត្រសកលដើម្បីបន្ថយទំហំនៃជំងឺមកពីចំណីអាហារ អង្គការសុខភាពពិភពលោក កំណត់នូវសេចក្តីត្រូវការដើម្បីទំនាក់ទំនងសារសុខភាពសកលសាមញ្ញ ជំរុញលើកទឹកចិត្តក្នុងភស្តុតាងវិទ្យាសាស្ត្រ ដើម្បីអប់រំគ្រប់ប្រភេទនៃអ្នកកាន់អាហារ រួមមានអ្នកប្រើប្រាស់ធម្មតា។ គន្លឹះ៥យ៉ាងដើម្បីចំណីអាហារមានសុវត្ថិភាពមាន:

- រក្សាការស្អាត
- ដាក់អោយដាច់ពីគ្នារវាងសាច់ស្រស់ និងសាច់ឆ្អិន
- ចំអិនដោយម៉ត់ចត់
- រក្សាទុកចំណីអាហារនៅសីតុណ្ហភាពសុវត្ថិភាព

ប្រើទឹក និងសំភារៈ ដែលមានសុវត្ថិភាព





សំរាប់ព័ត៌មានជាផ្លូវការអំពីការវិវត្តន៍របស់វីរុសផ្តាសាយប្រភេទ A (H1N1) និងសំរាប់ការណែនាំបច្ចេកទេស សំរាប់អ្នកគ្រប់គ្រងសេវាសុខភាព អ្នកជំនាញផ្នែកសុខភាព និងសាធារណៈជនទូទៅ សូមចូលមើល :

វ៉ិបសាយសកលរបស់ WHO :
http://www.who.int/csr/disease/influenza/pandemic/en/index.html

**សំរាប់ព័តិមានក្នុងប្រទេស :**

វ៉ិបសាយរបស់ក្រសួងសុខាភិបាល :
http://www.cdcmoh.gov.kh
វ៉ិបសាយរបស់អង្គការសហប្រជាជាតិ នៅក្នុងប្រទេសកម្ពុជា :
http://www.un.org.kh





## ចំនុចសំខាន់ៗដែលត្រូវនិយាយ សំរាប់អ្នកនាំពាក្យ :

### ១.តើរាជរដ្ឋាភិបាលកំពុងធ្វើអ្វីខ្លះ ដើម្បីត្រៀមសំរាប់ការរាតត្បាតជាសកលនៃជំងឺផ្តាសាយ?

រដ្ឋាភិបាលបាននឹងកំពុងត្រៀមសំរាប់ការរាតត្បាតជាសកលដែលអាចកើតមានឡើង ហើយឥឡូវនេះកំពុង ចាប់ផ្តើមអនុវត្តផែនការឆ្លើយតបទៅនឹងការរាតត្បាតជាសកលរបស់ខ្លួន។ រាជរដ្ឋាភិបាលកម្ពុជាកំពុងមាន ការត្រៀមប្រុងប្រយ័ត្នខ្ពស់ លើករណីខុសធម្មតានៃជំងឺស្រដៀងនឹងផ្តាសាយ ឬ ករណីជំងឺរលាកសួតធ្ងន់ធ្ងរ។ ក្រសួងសុខាភិបាល ក៏បានតំឡើងម៉ាស៊ីនស្កេនកំដៅនៅអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ និងសៀមរាប ហើយ បានផ្តល់ប័ណ្ណសុខភាពសំរាប់អ្នកធ្វើដំណើរដើម្បីអោយ អ្នកធ្វើដំណើរដែលមកដល់បំពេញ ដែលនេះជា ផ្នែកមួយនៃការអង្កេតតាមដានជាប្រចាំលើវីរុសនេះ។ ក្រសួងសុខាភិបាលក៏កំពុងរៀបចំនីតិវិធីប្រតិបត្តិការ និង គោលការណ៍ណែនាំសំរាប់បុគ្គលិកសុខាភិបាលផងដែរ ដោយសហការជាមួយនឹងគណកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ។

### ២.តើរាជរដ្ឋាភិបាលកំពុងធ្វើអ្វីខ្លះ ដើម្បីជូនដំណឹងដល់សាធារណៈជន អំពីការគំរាមកំហែង នៃការរាតត្បាតជាសកលនៃជំងឺផ្តាសាយ?

រដ្ឋាភិបាលបានកោះប្រជុំគណៈកម្មាធិការជាតិសំរបសំរួលព័ត៌មាន ការអប់រំ និងការប្រាស្រ័យទាក់ទង ដើម្បី អនុវត្តយុទ្ធសាស្រ្តអប់រំផ្សព្វផ្សាយថ្នាក់ជាតិអំពីជំងឺផ្តាសាយមនុស្សដែលមានស្រាប់។ គណៈកម្មាធិការនេះ ត្រូវបានបង្កើតឡើង នៅក្នុងឆ្នាំ ២០០៦ ដើម្បីធានាអោយមានការសំរបសំរួល និងការបញ្ជូនសារដែលមាន ប្រសិទ្ធភាពដល់សាធារណៈជន។

រដ្ឋាភិបាលនិងគ្រប់ដៃគូទាំងអស់នឹងជូនដំណឹងដល់សាធារណៈជនបន្ថែមទៀត នៅពេលមានព័ត៌មានថ្មីៗ។

### ៣.តើមានអនុសាសន៍អំពីសុខភាពសាធារណៈអ្វីខ្លះដើម្បីបង្ការមិនអោយមានការឆ្លង រាលដាលជំងឺផ្តាសាយប្រភេទ A (H1N1)?

ដើម្បីការពារខ្លួនឯងនិងអ្នកដទៃ សាធារណៈជនទាំងអស់គួរធ្វើអនុវត្តតាមទំលាប់សុខភាពល្អៗនិងបង្រៀន ទំលាប់ល្អៗ ទាំងនេះដល់កូនៗ។

- ខ្ទប់មាត់និងច្រមុះជាមួយក្រដាស ឬកែងដៃ នៅពេលក្អក និងកណ្តាស
- លាងដៃអោយបានញឹកញាប់ជាមួយសាប៊ូ

- កុំខាកស្តោះ នៅតាមទីសាធារណៈ

### ៤.តើសាធារណៈជនគួរធ្វើអ្វីខ្លះ ប្រសិនបើពួកគេគិតថា ពួកគេអាចមានជំងឺផ្តាសាយ ប្រភេទ A?

សាធារណៈជន ដែលបានធ្វើដំណើរទៅកាន់តំបន់មានជំងឺឬដែលធ្លាប់ប៉ះពាល់ជាមួយអ្នកដែលមានជំងឺ គួរ ស្នាក់នៅក្នុងផ្ទះ ហើយត្រូវទូរស័ព្ទទៅកាន់លេខទូរស័ព្ទទាន់ហេតុការណ៍ត្រៀមបង្ការការរាតត្បាតជាសកល របស់ក្រសួងសុខាភិបាល **០១២ ៤៨៩ ៩៨១** ឬ **០៨៩ ៦៦៩ ៩៦៧** ដើម្បីសុំជំបូន្មាន។ ធ្វើនៅថ្ងៃ ពុធ ទី ២០ ខែ ឧសភា ឆ្នាំ ២០០៩

## របាយការណ៍ចំនួនករណីផ្តាសាយថ្មី A (H1N1) លើពិភពលោក

ចំនួនករណីផ្តាសាយប្រភេទ A (H1N1) លើពិភពលោកកើនដល់ ២១ ៩៤០ ករណី ដែលក្នុងនោះស្លាប់ ១២៥ ករណី មានលើប្រទេសចំនួន ៦៩ នេះបើតាមសេចក្តីរាយការណ៍ពីអង្គការសុខភាពពិភពលោក។ ដោយឡែកមកទល់បច្ចុប្បន្ននេះ ប្រទេសកម្ពុជាមិនមានករណីជំងឺនេះកើតមាននៅឡើយ។ បណ្តាប្រទេសដែលមានករណីកើតមានឡើង ប៉ុន្តែមិនមាន ករណីស្លាប់ទេ រួមមាន ប្រទេសអាហ្សង់ទីណា (២០២ករណី) ប្រទេស អូស្ត្រាលី (១០៩១ករណី ) ប្រទេស អូទ្រីស្ត (៥ករណី) ប្រទេស បាហាម៉ាស(១ករណី) បារេន(១ករណី) បាបាដូស(២ករណី) ប៉ែលស្សិច(១៤ករណី) បូលីវៀ(៣ករណី) ប្រេស៊ីល (៣៥ករណី) ប៊ុលហ្គារី(២ករណី) កោះកៃម៉ាន (១ករណី) ប្រទេសចិន (១០៨ករណី) កូឡុំបៀ(២៥ករណី) ប្រទេសគុយបា (៥ករណី) ប្រទេសជីប៉ូស(១ករណី) សាធារណៈរដ្ឋស្លិធ (២ករណី) ប្រទេស ដែនម៉ាក(៧ករណី ) ប្រទេសដូមីនីកា (១ករណី) ប្រទេសអេខ្វាឌ័រ (៦០ករណី) ប្រទេសអេស៊ីប (១ករណី) ប្រទេសសាល់វ៉ាឌ័រ (៦៩ករណី) ប្រទេសអេស្តូនៀ (៣ករណី) ប្រទេសហ្វាំងឡង់ (៤ករណី) ប្រទេសបារាំង (៥៨ករណី) ប្រទេសអាឡឺម៉ង់ (៦៣ករណី) ប្រទេសហ្គេច (៥ករណី) ប្រទេស ហ្គាតេម៉ាឡា (៣០ករណី) ប្រទេសហុងដូរាស (៣៤ករណី) ប្រទេសហុងហ្គារី (៣ករណី) ប្រទេសអាយឡែន (១ករណី) ប្រទេសឥណ្ឌា (៤ករណី) ប្រទេសអៀរឡង់ (១១ករណី) ប្រទេសអ៊ីស្រាអែល ( ៥៤ ករណី) ប្រទេស អ៊ីតាលី (៥០ករណី ) ប្រទេសចាម៉ៃកា(៤ករណី) ប្រទេស ជប៉ុន (៤១០ករណី ) ប្រទេស កូរ៉េ (៤៧ករណី ) ប្រទេសគុយវ៉ែត (១៨ករណី) ប្រទេសឡេបានុន (៣ករណី) ប្រទេសលុចសម្បួរ (១ករណី) ប្រទេសម៉ាឡេស៊ី (៥ករណី) ប្រទេស នេឌឺឡែន(១០ករណី ) ប្រទេស ញ៉ូហ្ស៊ីឡែន (១៤ករណី ) ប្រទេសនីការាហ្គា (១៨ករណី) ប្រទេស ន័រវេ៉ (៩ករណី ) ប្រទេសបាណាម៉ា (១៧៩ករណី) ប្រទេស ប៉ារ៉ាហ្គាយ (៥ករណី) ប្រទេសប៉េរ៉ូ (៦១ករណី) ប្រទេសហ្វីលីពីន (៣៣ករណី) ប្រទេស ប៉ូឡូញ់ (៥ករណី ) ប្រទេស ប៊័រទុយហ្គាល់ (២ករណី ) ប្រទេសរូម៉ានៀ (៩ករណី) ប្រទេសរុស្ស៊ី (៣ករណី) ប្រទេសអារ៉ាប់ (១ករណី) ប្រទេសសាំងហ្គាពួរ (១៥ករណី) ប្រទេសស្លូវ៉ាគី (៣ករណី) ប្រទេស អេស្ប៉ាញ (២៩១ករណី) ប្រទេស ស៊្វីឌិន (១៤ករណី ) ប្រទេស ស្វីហ្ស៊ីឡែន (១៦ករណី ) ប្រទេស ថៃឡង់ដ៏ (៨ករណី ) ប្រទេសទ្រីនីដា និងតូបាហ្គូ (២ករណី) ប្រទេសតួគី (១០ករណី) សហរដ្ឋអារ៉ាប់ (១ករណី) សហរាជាណាចក្រ " ប្រទេសអង់គ្លេស និងអៀរឡង់ខាងជើង (៥៥៧ករណី) " និង ប្រទេសអ៊ុយរូហ្គាយ (១៧ករណី) ប្រទេសវេនេស៊ុយអេឡា (៤ករណី) ប្រទេសវៀតណាម (៩ករណី) ។ កាណាដា(២១១៥ករណី ស្លាប់៣ករណី) ឈីលី(៤១១ករណី ស្លាប់១ករណី) កូស្តារីកា(៦៨ករណី ស្លាប់១ករណី) (៦៨ករណី ស្លាប់១ករណី) ប្រទេសសាធារណៈ រដ្ឋដូមីនីកា (៤៤ករណី ស្លាប់ ១ករណី) ប្រទេសម៉ិចស៊ិកូ (៥៧១៧ ករណី ស្លាប់ ១០៦ករណី) និង សហរដ្ឋអាមេរិក (១៣២១៧ករណី ស្លាប់ ២៧ករណី ) អត្ថបទដកស្រង់ពី http://www.who.int/csr/disease/swineflu/en/index.html

# New Influenza A (H1N1), Number of laboratory confirmed cases as reported to WHO

***Status as of 08 June 2009 06:00 GMT***




The boundaries and names shown and the designations used on this map do not imply the expression of any opinion whatsoever on the part of the World Health Organization concerning the legal status of any country, territory, city or area or of its authorities, or concerning the delimitation of its frontiers or boundaries. Dotted lines on maps represent approximate border lines for which there may not yet be full agreement.

Data Source: World Health Organization
Map Production: Public Health Information and Geographic Information Systems (GIS)
World Health Organization

World Health Organization

© WHO 2009. All rights reserved

*Map produced: 08 June 2009 06:30 GMT*